**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 28-Sep-2012, 11:16
CMS/CFO: Uch Arun

**<u>ព័ត៌មានពិស្តារអំពីការដាក់ឯកសារ</u>**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសស

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១២

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងបទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយសាក្សី TCW-428**

---

<u>ដាក់ដោយ</u>៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

មេធាវី Jacques VERGÈS

<u>ដាក់ជូន</u>៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ូរ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

កញ្ញា Mathilde CHIFFERT

កញ្ញា អ៊ូច ស្រីផាត់

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្ដីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានស្នើសុំដាក់ចូលទៅក្នុងសំណុំរឿង និង ដាក់នៅចំពោះមុខអង្គជំនុំជម្រះ នូវប្រតិចារឹកនៃបទសម្ភាសន៍នាថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១០ របស់ មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយសាក្សី TCW-428 ផ្អែកតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង[1]។

២. នៅថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានទទួលការជូនដំណឹងអំពីចេតនារបស់លោក អៀង សារី ក្នុងការដកការលះបង់សិទ្ធិមានវត្តមានក្នុងសវនាការស្តាប់សក្ខីកម្មសាក្សី TCW-428។ មេធាវីការពារក្តីលោក អៀង សារី បានបញ្ជាក់ថា *"សាក្សី TCW-428 ឆ្លើយពាក់ព័ន្ធនឹងអំពើ និង អត្តចរិតរបស់លោក អៀង សារី (...)។ បញ្ហានេះមិនមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី ទាំងបីលើក ដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតនោះទេ"*[2]។

៣. ថ្ងៃនេះ មេធាវីការពារក្តីលោក ខៀវ សំផន សូមជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា និង ស្នើអង្គជំនុំជម្រះកុំស្តាប់ចម្លើយសាក្សី TCW-428 ជាដាច់ខាត ដរាបណាលោក អៀង សារី មិន មានលទ្ធភាពចូលរួមសវនាការពាក់ព័ន្ធនឹងការបង្ហាញខ្លួនរបស់សាក្សីនេះ។

៤. សំណើរបស់សហព្រះរាជអាជ្ញាស្តែងឲ្យឃើញថា ប្រតិចារឹកនៃបទសម្ភាសន៍ជាមួយសាក្សី TCW-428 ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា រកបានតាំងពីពាក់កណ្តាលខែ សីហា ឆ្នាំ ២០១១ ក្រោយ ពេលបើកការជំនុំជម្រះក្តី[3]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះបានបញ្ជាក់ថា សញ្ញាណនៃ "ភាពអាចរកបាន"

---

[1] សំណើរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន ៨៧(៤) ទាក់ទងនឹងបទសម្ភាសន៍របស់ DC-CAM ទៅលើសាក្សី TCW-428 ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារ E233/1 ("សំណើ")។

[2] លិខិតរបស់មេធាវីការពារក្តីលោក អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះ ស្តីពី *"ការដកការលះបង់សិទ្ធិមានវត្តមានក្នុងសវនាការស្តាប់សក្ខីកម្មសាក្សី TCW-428 របស់លោក អៀង សារី"* ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១២។

[3] សំណើ កថាខណ្ឌ ២។

នូវភស្តុតាងត្រូវតែមានទំនាក់ទំនងនឹងការខំខ្នះខ្នែងអស់ពីលទ្ធភាព[4]។ អង្គជំនុំជម្រះបានគូសបញ្ជាក់យ៉ាងច្បាស់ថា៖

"រយៈពេលអូសបន្លាយ រវាងការចាត់វិធានការជាក់ស្តែងសំដៅទទួលបានឯកសារ ឬភាពយឺតយ៉ាវមិនសមហេតុផល រវាងពេលរកឃើញឯកសារ និងការដាក់ពាក្យសុំឱ្យទទួលយកឯកសារនោះជាភស្តុតាង អាចបង្ហាញថាភាគីស្នើសុំមិនបានខំខ្នះខ្នែងអស់ពីលទ្ធភាព"[5]។

៥. សហព្រះរាជអាជ្ញាពិតជាមិនបានខំខ្នះខ្នែងអស់ពីលទ្ធភាពមែន។ ទោះបីជាសហព្រះរាជអាជ្ញាបញ្ជាក់ថា សំណើរបស់ខ្លួនត្រូវបានដាក់ "តាំងពីថ្ងៃដំបូង ក្រោយពីអង្គជំនុំជម្រះបានជូនដំណឹងអំពីកាលបរិច្ឆេទដែលបានកំណត់យកសម្រាប់ការស្តាប់ចម្លើយសាក្សី"[6] ក៏ដោយ ក៏សហព្រះរាជអាជ្ញាមិនដែលបានពន្យល់ថា ហេតុអ្វីក៏ខ្លួនមិនដាក់ពាក្យសុំតាំងពីយូរ បែរជាទើបតែមកដាក់ នៅចុងខែ កញ្ញា ឆ្នាំ ២០១២ នេះទៅវិញ។

៦. នៅខែ មករា ឆ្នាំ ២០១១[7] សហព្រះរាជអាជ្ញាបានស្នើសុំឱ្យកោះហៅសាក្សីនេះចូលមកបង្ហាញខ្លួន ហើយបានទទួលការជូនដំណឹងអំពីចេតនារបស់អង្គជំនុំជម្រះ ក្នុងការកោះហៅសាក្សីនេះឱ្យមកបង្ហាញខ្លួន នៅខែ តុលា ឆ្នាំ ២០១១[8]។ កង្វះភាពខ្នះខ្នែងស្តែងឡើងយ៉ាងច្បាស់ ដោយសារតែសហព្រះរាជអាជ្ញា "កត់សម្គាល់ផងដែរថា អនុលោមតាមយុត្តិសាស្ត្រអន្តរជាតិ ខ្លួនមានទម្លាប់ផ្តល់ជូន

---

[4] សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E190 កថាខណ្ឌ ២៣។

[5] យោងដូចខាងលើ។

[6] សំណើ កថាខណ្ឌ ៤។

[7] បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជអាជ្ញា រួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១, ទី២, ទី៣, ទី៣ក, ទី៤ និងទី៥ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ ឯកសារ E9/4។ សូមមើលឧបសម្ព័ន្ធទី៣៖ *បញ្ជីឈ្មោះសាក្សីរបស់ការិយាល័យសហព្រះរាជអាជ្ញា* ឯកសារ E9/4.3 ទំព័រ ១៦ លេខរៀងទី ១១០ នៃតារាង (P-106)។

[8] បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង, ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5 ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E131/1។ សូមមើលឧបសម្ព័ន្ធសម្ងាត់ ក ឯកសារ E131/1.1 ទំព័រ ៣ លេខរៀងទី ២០ នៃតារាង (TCW-428)។

មេធាវីការពារក្តី ប្រសិនបើខ្លួនដឹង នូវចម្លើយមុនៗរបស់សាក្សីដែលត្រូវកោះហៅឲ្យមកបង្ហាញខ្លួននៅក្នុងសវនាការ”[9]។

៧. ប្រតិចារឹកនៃបទសម្ភាសន៍ជាមួយសាក្សី TCW-428 ត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាប្រភពផ្តល់ឯកសារដ៏សំខាន់មួយរបស់តុលាការ និងសហព្រះរាជអាជ្ញា ផ្តល់ជូនតាំងពីខែ សីហា ឆ្នាំ ២០១១។ ដូច្នេះ ប្រសិនបើសហព្រះរាជអាជ្ញាពិតជាប្រឹងប្រែងក្នុងការផ្តល់ជូននូវចម្លើយមុនៗរបស់សាក្សីដែលត្រូវកោះហៅឲ្យមកបង្ហាញខ្លួនមែននោះ ហេតុអ្វីក៏ខ្លួនមិនដាក់ពាក្យសុំតាំងពីពេលអង្គជំនុំជម្រះជូនដំណឹង នៅខែ តុលា ឆ្នាំ ២០១១ អំពីចេតនាក្នុងការស្តាប់សក្ខីកម្មសាក្សីនេះ ដែលមាននៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញាតាំងពីយូរយារណាស់មកហើយ។

៨. ម្យ៉ាងវិញទៀត ទោះបីជាអង្គជំនុំជម្រះបដិសេធសំណើរបស់សហព្រះរាជអាជ្ញាក៏ដោយ ក៏អង្គជំនុំជម្រះមិនត្រូវស្តាប់សក្ខីកម្មសាក្សី TCW-428 ឡើយ ដរាបណាលោក អៀង សារី មិនមានលទ្ធភាពចូលរួមសវនាការពាក់ព័ន្ធនឹងការចូលមកបង្ហាញខ្លួនរបស់សាក្សីនេះ។

៩. ទោះបីជាប្រតិចារឹកនៃបទសម្ភាសន៍ជាមួយសាក្សី TCW-428 មិនត្រូវបានទទួលយកជាភ័ស្តុតាងថ្មី ក៏ដោយ ក៏ខ្លឹមសារនៃបទសម្ភាសន៍នៅតែអាចត្រូវបានប្រើប្រាស់ នៅពេលស្តាប់សក្ខីកម្មសាក្សីនេះ[10]។ ក៏ប៉ុន្តែ ឥឡូវនេះ ភាគីនានា និងអង្គជំនុំជម្រះ ដឹងថាសាក្សីនេះអាចនឹងផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងអំពើ និងអត្តចរិតរបស់លោក អៀង សារី។ ដូច្នេះ អនុលោមតាមកថាខណ្ឌ ១ និងកថាខណ្ឌ ៥ នៃវិធាន ៨១ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះមិនត្រូវស្តាប់សក្ខីកម្មសាក្សីនេះឡើយ ដរាបណាលោក អៀង សារី មិនមានលទ្ធភាពចូលរួមសវនាការ។

---

[9] សំណើ កថាខណ្ឌ ៤។

[10] ជាឧទាហរណ៍ សូមមើល៖ ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំផ្តល់ឯកសារក្នុងសំណុំរឿង ០០២ ទៅអ្នកជំនាញ (ឯកសារ E172/24/2) និងសំណើរបស់ អៀង សារី ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងឯកសារដែលត្រូវប្រើប្រាស់ក្នុងអំឡុងពេលនៃការសួរដេញដោលអ្នកជំនាញ David CHANDLER (E172/24/3) ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារ E172/24/4 កថាខណ្ឌ ៦។

១០. **អាស្រ័យហេតុនេះ** មេធាវីការពារក្តីលោក ខៀវ សំផន ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង បដិសេធសំណើរបស់សហព្រះរាជអាជ្ញា និងមិនត្រូវស្តាប់សក្ខីកម្មសាក្សី TCW-428 ឡើយ ដរាបណាលោក អៀង សារី មិនមានលទ្ធភាពចូលរួមសវនាការពាក់ព័ន្ធនឹងការចូលមកបង្ហាញខ្លួនរបស់សាក្សីនេះ។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ<br><br>មេធាវី Arthur VERCKEN<br><br>មេធាវី Jacques VERGÈS | ទីក្រុងភ្នំពេញ<br><br>ទីក្រុងភ្នំពេញ<br><br>ទីក្រុងប៉ារីស<br><br>ទីក្រុងប៉ារីស | *[ហត្ថលេខា]*<br><br>*[ហត្ថលេខា]*<br><br>*[ហត្ថលេខា]*<br><br>*[ហត្ថលេខា]* |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |